ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

National Center for Parasitology Entomology and Malaria Control

# កិច្ចប្រជុំបន្ទាន់ ការខារពង្រឹងការគ្រប់គ្រងជំងឺគ្រុនឈាម

រាជធានីភ្នំពេញថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥

## រួមគ្នាធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រសិទ្ធភាព


បណ្ឌិត ហ៊ុយ រ៉េកុល

ប្រធាន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

# មាតិកា

- អ្វីជាជំងឺគ្រុនឈាម
- ស្ថានភាពជំងឺគ្រុនឈាម &វឌ្ឍនភាព
- ចំនុចខ្លាំង & កត្តាប្រឈម
- ដំណោះស្រាយ និងអន្តរាគមន៍ជាយុទ្ធសាស្ត្រ
- ថ្លែងអំណរគុណ

# អ្វីជាជំងឺគ្រុនឈាម ?

- ជំងឺគ្រុនឈាម (Dengue) ជាពាក្យហៅទូទៅ ដែលក្នុងនោះបង្កប់នូវពាក្យបច្ចេកទេសមានចំណាត់ថ្នាក់ជា គ្រុនដាំង (Dengue Fever – DF) និង គ្រុនឈាម (Dengue Hemorrhagic Fever – DHF)។
- ជំងឺគ្រុនឈាម បង្កដោយវីរុសគ្រុនឈាមតាមរយៈការខាំចម្លងដោយសត្វមូសខ្លាញី។



**វីរុសគ្រុនឈាម** ( DNV )៖ មាន ៤ ប្រភេទ (សេរ៉ូទីប- 4 Serotypes) ជាគ្រួសារ Flaviviruses

√ សេរ៉ូទីណាមួយចូលក្នុងខ្លួនមនុស្ស លើកដំបូង គេហៅថា គ្រុនដាំង ( DF ) ៖ មិនប៉ះពាល់ដល់អាយុជីវិតទេ

√ សេរ៉ូទីណាមួយថ្មីចូលក្នុងខ្លួនមនុស្ស ខុសពីសេរ៉ូទីបលើកដំបូង គេហៅថា គ្រុនឈាម ( DHF ) ៖ អាចប៉ះពាល់ដល់អាយុជីវិតគ្រប់ពេល

√ សេរ៉ូទីបទាំង៤នេះ អាចឱ្យមួយជីវិតមនុស្សឈឺ ១ដងDF និង ៣ដងDHF ( សរុប គឺ៤ដង ) ដែលបង្កើតបានជាភាពស៊ាំ ឬវដ្ត ( ជុំ ) ៤ - ៦ឆ្នាំ ( Community Hert Immunity )

**សត្វមូសខ្លាញី** ( Aedes )៖ មាន ២ ប្រភេទចំបង Aedes Aezypti & Aedes Albopictus



✓ មូស ៖ ខាំបឺតឈាមមនុស្សជាចំបង ២-៣ នាក់ដើម្បីញាស់ពងម្តងៗ និង ចូលចិត្តខាំអំឡុងពេលថ្ងៃកន្លែងមិនមានពន្លឺថ្ងៃគ្រប់

✓ ជង្ហូរទឹក៖ មូសចូលចិត្តពងតោងផ្ទៃភាជន៍មានទឹកដែលរង ថ្លា គ្មានក្លិនស្អុយ គ្មានពណ៌ ដូចជា ពាង/អាងទឹកប្រើប្រាស់ និងសំភារៈទុកចោលពាសវាលពាសកាលដក់ទឹក ពិសេស៖ សំបកកង់ ពាង អាង ក្រឡ កែវ ចាន កំប៉ុង ត្រឡោកដូង ថូផ្កា ចានទឹកទម្រ .។ល។ ( សំបកកង់ឡានដើរតួ ១១ដងជាងគេ )

✓ បរិស្ថាន និងអកាសធាតុ៖ ភ្លៀងកើនជំងឺ២ដងជាងរដូវប្រាំង , កំពស់ទឹកភ្លៀងកើន១ម.ម គឺកើនជំងឺ១១% , ភ្លៀងប្រចាំថ្ងៃ គឺកើន៨%,

# ទីតាំងមូសភ្ញាស់ពង និង ដង្កូវទឹក


























# អ្នកជំងឺគ្រុនឈាម

- ជំងឺគ្រុនឈាម អាចមានរោគសញ្ញាបឋម បន្ទាប់ពីបានចម្លងវីរុសគ្រុនឈាមចូលក្នុងខ្លួនពី ៤ - ១០ ថ្ងៃ រួមមាន៖ គ្រុនក្តៅខ្លាំង (high Fever), និងអាចអមដោយ ឈឺខ្លួនប្រាណ (body aches), ឈឺសន្លាក់ (arthralgia), ឈឺក្រោយភ្នែក (retro-orbital headache), កន្ទួលក្រហមរមាស់ (rash), and ចង្អោរ (nausea) ជាដើម ឬមានសញ្ញាចេញឈាម ឬច្រើនជាងនេះ ទៅតាមសភាពធ្ងន់ធ្ងរនៃការវិវត្តជំងឺ។
- **គ្រុនឈាមធ្ងន់ធ្ងរ** (DHF shock syndrome) អាចយាយីដល់អាយុជីវិតគ្រប់ពេល។
- គ្រុនឈាម **គ្មានថ្នាំពិសេស**ណាមួយសម្លាប់មេរោគវីរុសនេះទេ តែត្រូវការការព្យាបាលថែទាំដ៏ត្រឹមត្រូវនូវរោគសញ្ញាពិសេសការបង្កប់ជាតិទឹក (fluid management) និងការព្យាបាលផលវិបាកក្លាយរោគផ្សេងៗដែលជះឥទ្ធិពលពីមេរោគ (Complications) លើប្រព័ន្ធសម្ពាធឈាម (Capillary permeability and extravascular fluid resorption) ដែលអាចបន្តរហូតដល់ ២អាទិត្យទើបជាសះស្បើយ។
- **វ៉ាក់សាំង**បង្ការជំងឺគ្រុនឈាមចុងក្រោយដែលអាចប្រើបាន គឺ Qdenga (Tak-003, WHO-PQ: May 2024) មានប្រសិទ្ធភាពទូទៅ ៨៦% លើក្រុមអាយុពី៦ឆ្នាំ - ១៦ឆ្នាំ តែមានហានិភ័យខ្ពស់សម្រាប់អ្នកមិនធ្លាប់ឆ្លង DNV-3 & DNV-4 (-16%, -106%)។

# ស្ថានភាពជំងឺគ្រុនឈាម សកល

- សកលលោកឆ្នាំ ២០២៤-WHO៖ ១៣៦ ប្រទេស បានរាយការណ៍ ១៤.២លានករណីឈឺ និង ៥២.០០០ករណីធ្ងន់ធ្ងរ និងស្លាប់ ១០.០០០នាក់។ ឆ្នាំ២០២៥ មានកំណើនខ្ពស់។




Figure 2: Dengue cases reported monthly from 2020-2025 (as of June 2025) in China
*Source: National Disease Control and Prevention Administration, China*

Figure 14. Number of new cases of dengue by month in Thailand from January 2018 to May 2025.









**Fig. 7: Global trends in annual reported dengue cases and deaths from 2010–2024**










Figure 9: Weekly reported cases of dengue-like illness (DLI) in French Polynesia
Source: WHO Division of Pacific Technical Support (Pacific Syndromic Surveillance System Weekly Bulletin)

# ស្ថានភាពជំងឺគ្រុនឈាម និងវឌ្ឍនភាព ព្រះរាជាណាចក្រកម្ពុជា

- **ប្រទេសកម្ពុជា ឆ្នាំ២០២៤៖** ជំងឺគ្រុនឈាមសរុបមាន ១៨ ៩៨៣ ករណី និងស្លាប់ ៤៦ នាក់ គឺបានទប់ស្កាត់បង្ការមិនឱ្យប្រជាជនឈឺប្រមាណជា ៣៤ ០១៧ នាក់ - ៥៤ ០១៧ នាក់ (ឬស្មើ ៦៤% - ៧៤%) នៃសន្ទស្សន៍ព្យាករណ៍ (៥៣ ០០០ - ៧៣ ០០០ ករណី)។




- **ប្រទេសកម្ពុជា ឆ្នាំ២០២៥៖**
  - ២៨សប្តាហ៍កន្លង មានជំងឺគ្រុនឈាមសរុប **១៧៧២៨ករណី** (IR: 101) គឺបានទប់ស្កាត់ ២៤៤៨៧នាក់ (ឬ៥៨%) បើប្រៀបនឹងសន្ទស្សន៍ព្យាករណ៍មាន៤២២១៥ករណី។ **ស្ថានភាពជំងឺកំពុងមានកំណើនរាល់សប្តាហ៍មិនទាន់ថយចុះ** (រំពឹងថានឹងចុះបន្ទាប់ពីសប្តាហ៍៣០)។
  - អត្រាស្លាប់ ០,២% (ស្លាប់៣២នាក់) ទាបជាងឆ្នាំ២០២៤ (មានអត្រា០,៣%)។



# ចំនុចខ្លាំង និង បញ្ហាប្រឈម

| ចំនុចខ្លាំង | បញ្ហាប្រឈម |
|---|---|
| 1. ជាង ៨៥% បានយល់ដឹងស្គាល់ពីជំងឺគ្រុនឈាម និង ប្រជាជនកង្វល់ពីសុខភាពបំនិនជីវិត | 1. នៅមានកម្រិតរបស់សហគមន៍ មិនទាន់មានការចូលរួមខ្ពស់អនុវត្តដាក់ស្តែងបង្ការការចំលងជំងឺគ្រុនឈាម (សំភារៈដក់ទឹកពាសវាលពាសកាលមានជង្គូវទឹក) → **សារអប់រំសុខភាព ?** |
| 2. រដ្ឋាភិបាល ក្រសួងសុខាភិបាល បានផ្តល់អាទិភាពផែនការថវិកា ធនធាន និងកៀរគរកិច្ចសហការ (ថ្នាំសម្លាប់ជង្គូវទឹក, ថ្នាំបាញ់សម្លាប់មូស, សេរ៉ូម, លិខិតប័ណ្ណសារអប់រំសុខភាព, សម្ភារៈ, ឱសថ, បរិក្ខារ, ពង្រឹកសមត្ថភាពវិជ្ជាជីវៈសុខាភិបាល, អភិបាលកិច្ច, និងកិច្ចសហការ ជាដើម) | 2. ប្រសិទ្ធភាពនៃអត្រាគ្របដណ្តប់ដោយមធ្យោបាយគ្រប់គ្រងភ្នាក់ងារចម្លង (ថ្នាំសម្លាប់ជង្គូវទឹក ឬបាញ់ថ្នាំ)<br>3. កិច្ចសហការអនុវត្តដាក់ស្តែង និងសមាហរណកម្មការងារលុបបំបាត់ប្រភពបង្កបង្កើតកូនចៅមូស<br> |
| 3. សេវាសុខាភិបាលកាន់តែប្រសើរទូលំទូលាយ ប្រសិទ្ធភាពមូលនិធិសមធម៌ ប្រព័ន្ធតាមដានជំងឺ (ប្រជាជនជឿជាក់វេជ្ជសាស្ត្រ ទាំងសេវារដ្ឋ/ឯកជន, ប្រជាជនយល់ពីសុខភាព ) | 4. អត្រា ០,២% ស្លាប់ដោយជំងឺគ្រុនឈាម គឺ៩៧% ជាកត្តាយឺតយ៉ាវចូលពេទ្យរដ្ឋលើសពី ៤៨ម៉ោង។ ក្រៅពីនេះអាចមានកត្តាៈ ក្មេងតូចៗ ក្មេងធាត់លើសគីឡូ ចាស់ជរា ការព្យាបាលដំបូងមិនត្រឹមត្រូវ .... ជាដើម) |

# យុទ្ធសាស្ត្រ និងដំណោះស្រាយ

| យុទ្ធសាស្ត្រ | ដំណោះស្រាយ |
|---|---|
| ១. កាត់បន្ថយអត្រាស្លាប់ | 1. សមត្ថភាពធ្វើរោគវិច្ឆ័យ ថែទាំព្យាបាល សង្គ្រោះ និងបញ្ជូន<br>2. ពង្រឹងលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន ស្វែងរកសេវាសុខាភិបាលមិនលើសពី ៤៨ម៉ោង បន្ទាប់ពីមានក្តៅខ្លួន និងមិនសាកល្បងព្យាបាលខុសសមត្ថភាពវិជ្ជាជីវៈ |
| ២. កាត់បន្ថយអត្រាឈឺ<br>(កាត់បន្ថយអត្រាឈឺ គឺបានន័យថាកាត់បន្ថយបន្ទុកជំងឺឱ្យទាបជាងវិសាលភាពសន្ទស្សន៍ព្យាករណ៍និន្នាការរីកសាយភាយជំងឺ ដោយមិនមានន័យថា បន្ទុកជំងឺបច្ចុប្បន្នត្រូវតែកាត់បន្ថយឱ្យទាបជាងឆ្នាំកន្លងនោះទេ) | 1. តាមដានជាប្រចាំនូវស្ថានភាពជំងឺ ដើម្បីកំណត់បានទីតាំងភូមិសាស្ត្រអន្តរាគមន៍ភ្លាមៗត្រឹមត្រូវទាន់ពេល.<br>2. ផ្ទៀងផ្ទាត់ឡើងវិញនូវរាល់ការងារអន្តរាគមន៍រួច ដើម្បីធានាបានប្រសិទ្ធភាពខ្ពស់ (**ជំហានបីនៃមធ្យោបាយដែលត្រូវធ្វើតាមលំដាប់គឺ** យុទ្ធនាការអប់រំផ្សព្វផ្សាយ អមជាមួយសកម្មភាពកំទេចចោលប្រភពដក់ទឹកមិនប្រើប្រាស់ → ដាក់ថ្នាំសម្លាប់ដង្កូវទឹក → បាញ់ថ្នាំសម្លាប់មូស បើចាំបាច់) |

# សេចក្តីថ្លែងអំណរគុណ !

- *សូមគោរពថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុត ជូនដល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលជាស្ថាបនិកសន្តិភាព និងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជាគតិបណ្ឌិតប៉ិនប្រសព្វថាមពលស្មោះភាពនយោបាយ ព្រមទាំងវីរៈកងកំលាំងទាំងអស់ កំពុងស្វាហាប់ការពារបូរណៈភាពទឹកដី !*
- សូមគោរពថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ ជូនដល់**សាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល** ដែលជាមគ្គុទ្ទេសក៍ដ៏ឆ្នើមក្នុងការដឹកនាំ ចង្អុលបង្ហាញ គាំទ្រជាប្រចាំ ដើម្បីសុខភាពគ្រប់គ្នា
- សូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំក្រសួងសុខាភិបាល ក្នុងការចង្អុលបង្ហាញ និងគាំទ្រ ដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ អោយសម្រេចបានគោលដៅជាបន្តបន្ទាប់
- សូមគោរពថ្លែងអំណរគុណ ដល់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក គ្រប់ជាន់ថ្នាក់របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ និងបុគ្គលិកមន្ត្រីរាជការថ្នាក់ក្រោមជាតិ រួមទាំងសេវាឯកជន ដែលបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុ សុខភាពប្រជាជនជាកង្វល់របស់យើង
- សូមគោរពថ្លែងអំណរគុណ ដល់ដៃគូជាតិ អន្តរជាតិ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធជាច្រើនទៀតដែលមិនបានរៀបរាប់ទីនេះ !